00636859

D427/4/14/corr-1

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 21 / 01 / 2011
ម៉ោង (Time/Heures): 10:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

# សំណើសុំការកែតម្រូវ

# Request for Correction

# Demande de Rectificatif

**សំណុំរឿងលេខ (Case/ Dossier):** 002/19-09-2007-ECCC/OCIJ (PTC104)

| **កែលើឯកសារលេខ:** **To Document No(s): Cote des documents à rectifier :** | **ERN(s):** | **កាលបរិច្ឆេទ: Request Date:** | **ប្រភេទកំណែ: Correction Type: Type de Correction:** |
|---|---|---|---|
| D427/4/14 | 00634911-00634915 Kh. | 13 -01-2011 | ☐ កែលើឯកសារដើម Change to Original Correction à apporter à l'original<br>☒ កែលើឯកសារបកប្រែ Change to Translation Correction à apporter à la traduction<br>☐ រៀបចំចាត់ថ្នាក់ឡើងវិញ Reclassification Nouveau classement |

| **មូលហេតុនៃការកែតម្រូវ (Reason for changes/ Explications):** |
|---|
| កំហុសបច្ចេកទេសក្នុងការវាយអក្ខរាវិរុទ្ធ។ |

| **សេចក្តីលម្អិតនៃការកែតម្រូវ (Details/ Détails):** |
|---|
| ក្រឡាបញ្ជីនៃ អបជ សូមស្នើកែតម្រូវអក្ខរាវិរុទ្ធ នៅត្រង់ទំព័រ៥ នៃសាលដីកាលើបណ្តឹងឧទ្ធរណ៍ របស់លោក ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ។ សូមមើល Track Change ដែលភ្ជាប់មកជាមួយ។ |

ភាគីស្នើសុំ:
**Filing Party/ Déposé par:**

ហត្ថលេខា
**Signature:** [signature]

បានទទួលការឯកភាពពីក្រឡាបញ្ជី(ចំពោះឯកសារដើម):
**Approved by Greffier (for originals):**
**Approuvé par le greffier (pour les originaux) :**

ហត្ថលេខា
**Signature:** Chanrath

បានទទួលការឯកភាពពីអង្គភាពបកប្រែភាសា(ចំពោះការបកប្រែ):
**Approved by ITU (for translations):**
**Approuvé par le Groupe d'interprétation et de traduction (pour la traduction) :**

ហត្ថលេខា:
**Signature:**

00636860

D427/4/14/Corr-1

**អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា(“**អ.វ.ត.ក**”)បានទទួល “បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ” ដែលបានដាក់ដោយ ខៀវ សំផន កាលពីថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០ (“បណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន”)[១]។

១. ម្ចាស់បណ្តឹងឧទ្ធរណ៍បានស្នើសុំអង្គបុរេជំនុំជម្រះឲ្យធ្វើការកត់សម្គាល់ថា ដីកាបញ្ជូនរឿងទៅជម្រះ ត្រូវបានចេញដោយរំលោភលើវិធាននៃកិច្ចស៊ើបសួរ ហើយបានបញ្ចប់មុនកាលកំណត់នូវកិច្ចស៊ើបសួរដែលមានលក្ខណៈមិនពេញលេញ និងធ្វើឡើងសម្រាប់តែដាក់បន្ទុកប៉ុណ្ណោះ[២]។ ម្ចាស់បណ្តឹងឧទ្ធរណ៍បានលើកឡើងក្នុងលក្ខណៈទូទៅថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះ មិនបានធ្វើឡើងដោយឆ្លងកាត់សវនាការតទល់គ្នាមួយឡើយ ដែលដីកានេះមិនបានគិតទៅដល់វិសាលភាព នៃទំនាក់ទំនងជាយថាហេតុរវាងគាត់ជាមួយនឹងអង្គហេតុដែលបានចោទប្រកាន់ ហើយដែលដីកានេះពុំបានអនុញ្ញាតឲ្យមានការបង្ហាញនូវការពិត និងការស៊ើបសួរផ្សេងៗទៀត ត្រូវតែធ្វើឡើងដោយខានមិនបាន ដើម្បីធានាឲ្យមានការជំនុំជម្រះសេចក្តីមួយប្រកបដោយគុណភាព[៣]។

២. ម្ចាស់បណ្តឹងឧទ្ធរណ៍បានលើកឡើងនូវអំណះអំណាងក្នុងការធ្វើបណ្តឹងឧទ្ធរណ៍ចំនួនពីរ។ អំណះអំណាងទីមួយលើកឡើងអំពីអវត្តមានសវនាការតទល់មុខគ្នា[៤] ដោយសារ (១) ការបដិសេធសិទ្ធិឆ្លើយតបទៅនឹងដីកាសន្និដ្ឋានស្ពាតរបស់សហព្រះរាជអាជ្ញា[៥], (២) អវត្តមាននៃភស្តុតាងជាភាសាបារាំង និងភាសាខ្មែរ[៦] និង (៣) ភាពពុំច្បាស់លាស់នៃកិច្ចដំណើរការរបស់សហចៅក្រមស៊ើបអង្កេត។ អំណះអំណាង

Formatted: Catalan

Deleted: នស

---

[១] បណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០ ឯកសារ D427/4/3 (“បណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន”)។

[២] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ១។

[៣] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ២។

[៤] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៦២ ដល់ ៨៤។

[៥] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៦៣ ដល់ ៦៨

[៦] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ៦៩ ដល់៧៣។

00636861



ក្នុងការធ្វើបណ្ដឹងឧទ្ធរណ៍ទីពីរបានលើកឡើងថា កិច្ចស៊ើបសួរមានលក្ខណៈមិនពេញលេញ លម្អៀង និង *បង្កគ្រោះថ្នាក់*។

៣. អង្គបុរេជំនុំជម្រះបានសម្រេចជាស្ថាពរលើបណ្ដឹងឧទ្ធរណ៍ ដូចដែលអង្គបុរេជំនុំជម្រះប្រកាស នៅពេលនេះ។ សេចក្ដីសម្រេចដែលមានសំអាងហេតុចំពោះបណ្ដឹងឧទ្ធរណ៍នេះ នឹងចេញទៅតាមពេលវេលាកំណត់។

**ដូច្នេះ អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆ័ន្ទ៖**

១. បណ្ដឹងឧទ្ធរណ៍មិនអាចទទួលយកបាន។

២. ជនជាប់ចោទត្រូវបានចោទប្រកាន់ និងត្រូវបានបង្គាប់ឲ្យបញ្ជូនខ្លួន ទៅជំនុំជម្រះ ដូចដែលបានចែង នៅក្នុងដីកាដំណោះស្រាយ(ដីការបញ្ជូនរឿងទៅជំនុំជម្រះ) ដែលត្រូវយកមកពិចារណារួមជាមួយនឹងសាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះ-ស្រាយ[៧] ព្រមទាំងសាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ[៨] ដែលអង្គបុរេជំនុំជម្រះប្រកាសនៅក្នុងថ្ងៃនេះ ចំពោះជនជាប់ចោទទាំងអស់នៅក្នុងរឿងនេះ ដោយដីកាដំណោះស្រាយត្រូវបានកែប្រែដូចខាងក្រោមនេះ៖

១. បន្ថែម "អត្ថិភាពនៃចំណងពាក់ព័ន្ធរវាងអំពើជាមូលដ្ឋាន និងជម្លោះប្រដាប់<u>អាវុធ</u>" ដែលជាលក្ខខណ្ឌតម្រូវ "ធាតុផ្សំ"មួយ នៅក្នុងផ្នែកទីIV(ក)នៃជំពូក៣ នៃដីកាដំណោះស្រាយ។

[៧] សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៣ ខែ មករា ឆ្នាំ២០១១ (អបជ ១៤៥ និង១៤៦)

[៨] សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង សារីប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៣ ខែ មករា ឆ្នាំ២០១១ (អបជ ៧៥)។